# សេចក្ដីថ្លែងការណ៍

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ វត្តខ្មែរកាណាដា អំពីអនុមោទនាការប្រកាសព្រះរាជទ្រព្យរបស់ព្រះមហាក្សត្រខ្មែរ

**Website: www.hoksavann.org**

ថ្ងៃទី១៧ កញ្ញា ២០០៤

នៅពេលថ្មីៗនេះ ព្រះមហាក្សត្រខ្មែរបានចេញព្រះរាជសារនៅក្នុងវែបសាយរបស់ព្រះអង្គ ប្រការព្រះរាជទ្រព្យព្រះអង្គ ដូចជាព្រះរាជដំណាក់និងហិរញ្ញវត្ថុ ដែលដំកល់នៅធនាគារបារាំងនិងធនាគារចិន ។ នេះជាលើកទីមួយ ដែលព្រះមហាក្សត្រខ្មែរបានប្រកាសព្រះរាជទ្រព្យរបស់ព្រះអង្គ ដើម្បីបញ្ជាក់អំពីភាពបរិសុទ្ធរបស់ព្រះអង្គក្នុងអំពើពុករលួយ ហើយនេះក៏បានជាគំរូដល់ឥស្សរជនខ្មែរដទៃទៀត ។ សូមអនុមោទនាត្រេកអរជាមួយនិងការកោតសរសើរ ចំពោះព្រះមហាក្សត្រខ្មែរ ដែលមានសេចក្ដីក្លាហានប្រកាសព្រះរាជទ្រព្យផ្ទាល់ខ្លួនព្រះអង្គ ដើម្បីកុំឲ្យមានការសង្ស័យអំពីអំពើពុករលួយ ដែលសព្វថ្ងៃមតិជាតិនិងអន្តរជាតិ ជាពិសេសអ្នកម្ចាស់ធ្វើអំណោយឲ្យអ្នកកាន់អំណាចខ្មែរកំចាត់អំពើទាំងនេះ ដើម្បីបំបាត់ភាពក្រីក្រនៃប្រជាពលរដ្ឋខ្មែរ ។

ជាមួយគ្នានេះ សូមស្នើរដ្ឋសភាខ្មែរ ដែលមានសមត្ថកិច្ចខាងការតាក់តែងច្បាប់និងអនុម័តច្បាប់ សូមពិនិត្យមើលសំណើ៣ខ ដែលសំណើនេះធ្លាប់បានស្នើម្ដងរួចមកហើយ ដែលមានអត្ថន័យដូចតទៅនេះ ៖

១- សូមតំណែងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលខ្មែរ ចំពោះបុគ្គលម្នាក់អនុញ្ញាតឲ្យកាន់តំណែងនេះបានតែពីរអាណត្តិ គឺអាណត្តិទី១និងអាណត្តិទី២ ហើយពុំអាចកាន់តំណែងនេះបានក្នុងអាណត្តិទី៣ឡើយ ។ ទំនើបែបនេះជាការប្រសើរណាស់ ជាការបើកឱកាសឲ្យបញ្ញវ័ន្តអ្នកចេះដឹងថ្មីៗទៀត ផ្លាស់ប្ដូរគ្នាធ្វើការបំរើជាតិឲ្យប្រទេសជឿនលឿនទៅមុខ ។

២- សូមសមាជិកនៃរាជរដ្ឋាភិបាល ចាប់តាំងពីនាយករដ្ឋមន្ត្រីរហូតមកដល់អនុរដ្ឋលេខាធិការ មុនឡើងកាន់តំណែងនិងពេលចុះចេញពីតំណែង ត្រូវប្រកាសទ្រព្យសម្បត្តិទាំងអស់របស់ខ្លួនដែលមានជាសាធារណៈ ។ ការប្រកាសនេះមានប្រយោជន៍ណាស់ ជាវិញ្ញាសារបញ្ជាក់អំពីភាពបរិសុទ្ធឬពុំបរិសុទ្ធ ពីអំពើពុករលួយរបស់សមាជិកនៃគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលខ្មែរ ។

៣- សូមសមាជិកនៃគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល រួមទាំងរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការផង មានភរិយាស្របច្បាប់តែម្នាក់ ហើយក៏មិនអនុញ្ញាតឲ្យមានភរិយាលួចលាក់ណាផ្សេងទៀតឡើយ ។ ការកំរិតចំនួនភរិយាដូច្នេះ ដើម្បីសំអាតអ្នកដឹកនាំ ឲ្យមានការសង្គោសក្នុងកាមគុណ ព្រោះអំពើពុករលួយមួយភាគ កើតចេញមកអំពីការមានភរិយាច្រើនដែលជំរុញឲ្យពុករលួយ ដើម្បីបានប្រាក់យកមកចិញ្ចឹមប្រពន្ធចុង។

មួយទៀត រដ្ឋសភាមុននឹងអនុម័តឲ្យសមាជិករដ្ឋាភិបាលណាម្នាក់ធ្វើជាគណៈរដ្ឋមន្ត្រី ត្រូវពិនិត្យមើលចរិយាមារយាទរបស់ស្ត្រីជាភរិយារបស់អស់លោកទាំងនោះផង ព្រោះភរិយាទុកដូចជាទីប្រឹក្សារបស់ស្វាមី ។ បើភរិយាមានគំនិតពុំល្អ អាចជំរុញស្វាមីឲ្យប្រព្រឹត្តអំពើពុករលួយ ។

សំណើទាំង៣នេះសំខាន់ណាស់ គួររដ្ឋសភាខ្មែរយកចិត្តទុកដាក់យកទៅពិចារណា ដោយមិនត្រូវគិតពីគណបក្សនយោបាយទេ គឺត្រូវគិតពីប្រយោជន៍ជាតិទៅអនាគត ។ ច្បាប់ធ្វើឡើងពុំមែនសំរាប់តែរដ្ឋាភិបាលអាណត្តិនេះទេ គឺសំរាប់អាណត្តិក្រោយៗទៀត មនុស្សកើតមកត្រូវស្លាប់ទៅវិញ ដូច្នេះបើច្បាប់ណាមានប្រយោជន៍ដល់ជាតិហើយ គួរនាំគ្នាអនុម័ត កុំរារាំងដោយសារតែប្រយោជន៍ផ្ទាល់ខ្លួនឬប្រយោជន៍គណបក្សឡើយ ។

ព្រះពុទ្ធសាសនាក៏ដូចជាផ្លូវអាណាចក្រ ការជ្រើសរើសអ្នកដឹកនាំជាតិ ត្រូវស្ថិតនៅលើមូលដ្ឋានវិជ្ជាសម្បត្តិនិងចរិយាសម្បត្តិ បានសេចក្ដីថាដើម្បីបានអ្នកដឹកនាំល្អ ទៅរកសេចក្ដីសុខចំរើន លុះត្រាតែអ្នកដឹកនាំនោះមានសមត្ថភាព និងមានគំនិតស្អាតស្អំ ។ យ៉ាងណាមិញ ដើម្បីដឹងថា អ្នកដឹកនាំខ្មែរមានសមត្ថភាពគ្រប់គ្រាន់ឬយ៉ាងណា មានគំនិតស្អាតស្អំ ពុំពុករលួយឬយ៉ាងណានោះ តោងពិនិត្យមើលលទ្ធផលនៃការងារកន្លងពីរអាណត្តិមកហើយ ។ ក្នុងរយៈកាលពីរអាណត្តិ មានវិជ្ជមានខ្លះដូចជាព្រះពុទ្ធសាសនាមានការចំរើនលូតលាស់គ្រាន់បើ ការនិយាយស្ដីក៏មានវិជ្ជមានខ្លះ ។ ប៉ុន្តែអវិជ្ជមានក៏មានច្រើនដែរ ព្រះពុទ្ធសាសនាបានលូតលាស់គ្រាន់បើ ដោយសារតែជនជាតិខ្មែរ ដែលរស់នៅបរទេសបានផ្ដល់ថវិកាទៅជួយកសាងសំណង់ផ្សេងៗ ដូចជាកុដិសាលាព្រះវិហារជាដើម ។ ព្រះសង្ឃមានសិទ្ធិនិយាយស្ដី ប៉ុន្តែកុំឲ្យនិយាយប៉ះពាល់ដល់អ្នកដឹកនាំ ។ អ្នកសារពត៌មានមានសិទ្ធិសរសេរ ប៉ុន្តែក៏មានគេលួចធ្វើឃាតក៏ច្រើននាក់ដែរ ។ បើចង់ដឹងថា ប្រជាពលរដ្ឋខ្មែរសព្វថ្ងៃនេះមានជីវភាពខ្ពង់ខ្ពស់ ឬមានជីវភាពកាន់តែទាបទៅៗ មិនត្រូវមើលតែអ្នកមាននៅទីក្រុងភ្នំពេញជាដើម ដែលមានចំនួនតែ៥ភាគរយប៉ុណ្ណោះ ប៉ុន្តែត្រូវពិនិត្យមើលប្រជាពលរដ្ឋនៅតាមស្រុកស្រែចំការ ដែលរស់នៅតាមជនបទដែលអង្គការជាច្រើនក្រុមបានបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរមានភាពក្រីក្ររកមិនបាន១ដុល្លារអាមេរិកផងក្នុង១ថ្ងៃ ។ មិនតែប៉ុណ្ណោះ អំពើអបាយមុខ ល្បែងស្រី ល្បែងស្រា ល្បែងភ្នាល់ បានកើតឡើងពាសពេញប្រទេស ។ រោគអេដ៍ក៏កាន់តែរីកចំរើនឡើង ។ អំពើហឹង្សាក៏កាន់តែកើនឡើង ។ ជំនួញស្ត្រីឲ្យបំរើផ្លូវភេទនិងជំនួញកុមារ ក៏នៅតែមាន ។ល។

មានគណបក្សមួយនិយាយថា គេមិនគិតពីបុគ្គលទេ គឺគេគិតពីគោលការណ៍ បានសេចក្ដីថា បុគ្គលអ្នកកាន់អំណាច បុគ្គលណាក៏បានដែរ ឲ្យតែអនុវត្តគោលការណ៍គឺកម្មវិធីនយោបាយបានជោគជ័យ ។ ទស្សនៈនេះពុំសមហេតុផលទេ ព្រោះបុគ្គលដែលអាចអនុវត្តគោលការណ៍មានប្រសិទ្ធិភាពនិងបានជោគជ័យ លុះត្រាតែបុគ្គលនោះមានសមត្ថភាពនិងមានចិត្តគំនិតស្អាតស្អំ ។ បានសេចក្ដីថា បុគ្គលមានសមត្ថភាពផង គោលការណ៍ល្អផង ទើបកិច្ចការនោះបានជោគជ័យ គឺត្រូវមានកត្តាទាំងពីរនេះជាដាច់ខាត គឺគោលការណ៍ល្អនិងអ្នកអនុវត្តគោលការណ៍ក៏ឲ្យបានត្រឹមត្រូវ ។ ឥឡូវនេះ គេគប្បីពិនិត្យមើលរដ្ឋាភិបាលខ្មែរ ដែលបានកាន់ការពីរអាណត្តិហើយ តែប្រជាពលរដ្ឋនៅតែក្រីក្រដដែល ។ ឆ្លងមកដល់អាណត្តិទីបីនេះទៀត នៅតែមនុស្សដដែល គណបក្សដដែល ដែលធ្វើរដ្ឋាភិបាលចំរុះ ។ តើមនុស្សដដែល គណបក្សដដែលដែលធ្វើរដ្ឋាភិបាលចំរុះនេះ អាចឲ្យប្រទេសកម្ពុជាមានការលូតលាស់ចំរើនឬទេ ទោះបីគេដឹងថា កម្មវិធីនយោបាយឬគោលការណ៍មានចំនួនច្រើនជាងមុនក៏ដោយ ។ ឥឡូវនេះ ប្រជាពលរដ្ឋខ្មែរគ្មានផ្លូវជំរើសទេ ត្រូវតោងរង់ចាំមើលរដ្ឋាភិបាលកញ្ចប់រំលោភរដ្ឋធម្មនុញ្ញនេះ តើនាំកម្ពុជាទៅទិសណាទៀត ។ បើសង្ឃឹមលើព្រះមហាក្សត្រខ្មែរ ព្រះអង្គមានបន្ទូលថា ព្រះអង្គគ្មានអំ-

ណាចចាត់ចែងទេ ។ ពីមុននេះ ពេលដែលគណបក្សមួយទៅគាល់ ព្រះមហាក្សត្រខ្មែរពោលសរសើរគណបក្សនោះ ហើយបង្អាប់គណបក្សមួយទៀតដែលអវត្តមាន ។ លុះពេលដែលគណបក្សដែលព្រះអង្គបង្អាប់នោះមកគាល់វិញ ព្រះអង្គសរសើរគណបក្សនោះ ហើយពោលបង្អាប់គណបក្សដែលព្រះអង្គសរសើរពីមុន, នេះគឺព្រះបិតាជាតិដែលព្រះអង្គឲ្យខុសឲ្យត្រូវក្នុងគណបក្សមួយចំនួន៥០%ស្មើគ្នា ដូច្នេះគណបក្សនីមួយៗ កុំតូចចិត្តអីត្រូវទទួលយកទៅ ឯខ្លួនព្រះអង្គវិញរួចខ្លួនហោង ។ ទាំងអស់គ្នានាំគ្នាធ្វើវិភាគឬបញ្ចេញទស្សនៈអំពីព្រះបន្ទូលយ៉ាងមុតមាំរបស់ព្រះមហាក្សត្រខ្មែរ ដែលថាព្រះអង្គនឹងដាក់រាជ្យ ឥឡូវនេះការធ្វើវិភាគឬបញ្ចេញទស្សនៈនោះគ្មានន័យអ្វីឡើយ ព្រោះបន្ទាប់ពីគណបក្សនីមួយៗទៅគាល់ ពាក្យថាដាក់រាជ្យត្រូវស្ងាត់សូន្យ ដូច្នេះអ្នកធ្វើវិភាគឬបញ្ចេញទស្សនៈនោះត្រូវតែបត់បែនឲ្យរហ័សទាន់សភាពការណ៍ ។ អំពីបញ្ហាដាក់រាជ្យដដែលនេះ កាលពីមុនព្រះអង្គមានព្រះបន្ទូលថា ការសំរេចឲ្យដាក់រាជ្យឬមិនឲ្យដាក់រាជ្យ ស្រេចទៅលើសម្តេចទេព-វង្ស បើសម្តេចទេព-វង្សអនុញ្ញាតឲ្យដាក់រាជ្យ ទើបព្រះអង្គដាក់ បើមិនអនុញ្ញាតទេ ព្រះអង្គមិនហ៊ានដាក់ទេ ព្រះអង្គមិនហ៊ានប្រឆាំងនឹងព្រះសង្ឃទេ ។ បើព្រះអង្គសំរេចព្រះទ័យប្រគាល់កិច្ចការដាក់រាជ្យនេះលើសម្តេចទេព-វង្ស ក៏ទុកដូចព្រះអង្គប្រគល់កិច្ចការនេះលើគណបក្សប្រជាជនកម្ពុជាដែរ ព្រោះសម្តេចទេព-វង្សនិងគណបក្សប្រជាជនកម្ពុជា ពិតជាមិនអនុញ្ញាតឲ្យព្រះអង្គដាក់រាជ្យឡើយ ដោយគេមើលឃើញថា ព្រះមហាក្សត្របច្ចុប្បន្ននេះនៅមានប្រយោជន៍ដល់គណបក្សរបស់គេ ។

ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ព្រះកាយវិការរបស់ព្រះមហាក្សត្រខ្មែរបច្ចុប្បន្ននេះ គួរឲ្យប្រជាពលរដ្ឋគោរពនិងកោតសរសើរ ដោយព្រះអង្គបានប្រកាសព្រះរាជទ្រព្យដែលមាន ដោយពុំលាក់លៀម ដែលបញ្ជាក់អំពីភាពបរិសុទ្ធរបស់ព្រះអង្គពីអំពើពុករលួយ ដូច្នេះឥស្សរជនខ្មែរដទៃទៀត គួរយកព្រះមហាក្សត្រខ្មែរជាគំរូ ហើយប្រកាសទ្រព្យសម្បត្តិរបស់ខ្លួន មុនឡើងកាន់តំណែងក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលខ្មែរ និងប្រកាសនៅពេលចុះចេញពីតំណែង ដើម្បីបញ្ជាក់អំពីបរិសុទ្ធភាពរបស់ខ្លួនក្នុងអំពើពុករលួយ ។៚

❑